# ភ្ជាប់ឡើងវិញទីក្រុងស៊ីតថលខាងលិច WEST SEATTLE
# ដំណើរការផ្តល់អាទិភាពដល់សង្កាត់ជិតខាង




ការបិទស្ពានអាកាសទីក្រុងស៊ីតថលខាងលិច (West Seattle High- Rise Bridge) ដែលមិនបានរំពឹងទុកមុន បានប៉ះពាល់យ៉ាងខ្លាំងដល់ទីក្រុងស៊ីតថលខាងលិច West Seattle និងសហគមន៍ Duwamish Valley ដែលនៅជិតនោះ ជាពិសេសអ្នកដែលនៅតាមបណ្តោយផ្លូវវាង។ ផលប៉ះពាល់ទាំងនេះ នឹងនៅតែបន្តកើនឡើង នៅពេលយើងខ្ញុំបានជាសះស្បើយឡើងវិញពីវីរុស COVID-19 រីករាលដាល។ ទោះបីជាមានបញ្ហាប្រឈមចំពោះការប្រាថ្នាចង់បានយ៉ាងខ្លាំង ការផ្លាស់ប្តូរ និងការសហការក៏ដោយ ក៏យើងខ្ញុំអាចភ្ជាប់ឡើងវិញទីក្រុងស៊ីតថលខាងលិច West Seattle ផងដែរ។ ការកំណត់គោលការណ៍តំបន់ទូលំទូលាយនេះ មានគោលបំណងប ង្កើនការចល័តទីកន្លែងសម្រាប់តំបន់ដែលមានផលប៉ះពាល់ទាំងអស់។ អ្វីដែលសំខាន់នោះ វាផ្តល់ជូនការគាំទ្របន្ថែមមួយកម្រិតទៀត សម្រាប់តំបន់ទាំងនោះ ដែលមានផលប៉ះពាល់ខ្លាំងបំផុត។

ពីសាលាក្រុងនិងវេទិកាសហគមន៍ចំនួនជាង 30 យើងខ្ញុំបានដឹងនិងបានប្រមូលសំណើនិងមតិយោបល់ដោយផ្ទាល់ពីសមាជិកសហគមន៍នៅ South Park, Georgetown, SODO, និង South West Seattle (Roxhill, Highland Park, Riverview, South Delridge) ដែលមានការព្រួយបារម្ភយ៉ាងខ្លាំងនិងត្រឹមត្រូវតាមច្បាប់អំពីរបៀបដែលពួកគេនឹងធ្វើដំណើរជុំវិញនៅទីនោះ  ភាពអាចមានរថយន្តក្រុង ការធ្វើចរាចរណ៍ឆ្លងកាត់ សុវត្ថិភាពអ្នកថ្មើរជើង និងការបំពុលបរិស្ថានកើនឡើងនៅសង្កាត់ជិតខាងរបស់ពួកគេ។ សហគមន៍ទាំងនេះ បានបញ្ហាប្រឈមនឹងផលប៉ះពាល់បរិស្ថានរួចទៅហើយ មុនពេលទទួលយកភាគច្រើននៃការធ្វើចរាចរណ៍និងការបំពុលបរិស្ថានបន្ទាប់ពីការបិទស្ពាននេះ។

ផ្នែកនៃការកំណត់គោលការណ៍ភ្ជាប់ឡើងវិញទីក្រុងស៊ីតថលខាងលិច (Reconnect West Seattle) អាចឱ្យសង្កាត់ជិតខាងរបស់អ្នកដឹកនាំនិងកំណត់អាទិភាពដល់គម្រោងណាមួយ ដែលអ្នកគិតថាជាសហគមន៍មួយនោះ នឹងកាត់បន្ថយផលប៉ះពាល់ច្រើនបំផុតពីការបិទស្ពានអាកាស High-Bridge និងការទាក់ទងនឹងផ្លូវវាងក្នុងរយៈពេលខ្លី និងរយៈពេលវែង។ SDOT ត្រៀមខ្លួនជាស្រេចដើម្បីបម្រើការងារ។

Seattle
Department of
Transportation

## ការបញ្ចេញមតិយោបល់របស់អ្នក ត្រូវការ៖ សូមបំពេញសន្លឹកឆ្នោតរបស់អ្នក

**South Park | Georgetown | SODO | Roxhill, Highland Park, Riverview, South Delridge**

ប្រសិនបើលោកអ្នករស់នៅឬធ្វើការនៅ South Park, Georgetown, SODO ឬ South West Seattle (Roxhill, Highland Park, Riverview, South Delridge) សូមបំពេញសន្លឹកឆ្នោតផ្តល់អាទិភាពដល់សង្កាត់ជិតខាងរបស់អ្នកនៅត្រឹមថ្ងៃទី 31 ខែកក្កដា ដើម្បីជូនដំណឹងដល់យើងខ្ញុំអំពីអ្វីដែលសង្កាត់ជិតខាងរបស់អ្នកត្រូវការបំផុត ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការបិទស្ពានអាកាស High-Bridge និងផ្លូវវាង។ សន្លឹកឆ្នោតអាចមាននៅលើគេហទំព័រគម្រោង៖ www.seattle.gov/reconnectwestseattle. ដើម្បីស្នើសុំសន្លឹកឆ្នោតជាភាសាផ្សេងទៀត ឬការសម្របសម្រួលឬជំនួយដែលសមហេតុផលផ្សេងទៀត សូមទាក់ទងមកយើងខ្ញុំតាម WestSeattleBridge@seattle.gov ឬតាមទូរស័ព្ទលេខ 206-400-7511។

យើងខ្ញុំចាប់អារម្មណ៍ខ្លាំងណាស់ចំពោះការរៀបចំឱ្យមានដំណើរការបញ្ចូលគ្នានេះ ហើយចង់ស្តាប់ពីសមាជិកសហគមន៍ទាំងអស់ ដែលរស់នៅឬធ្វើការនៅសង្កាត់ជិតខាងទាំងនេះ។ ជាពិសេសយើង ខ្ញុំត្រូវចំណាយពេលវេលាស្តាប់ពីប្រជាពលរដ្ឋដែលតាមធម្មតាមិនពាក់ព័ន្ធនឹងការសន្ទនាទាំងនេះកាលពីពេលមុន។ ដូចច្នេះយើងខ្ញុំសូមជម្រុញលើកទឹកចិត្តលោកអ្នកឱ្យចែករំលែកសន្លឹកឆ្នោតទាំងនេះឱ្យបានទូលំទូលាយ។

## បញ្ជីគម្រោង

បញ្ជីគម្រោងសក្តានុពលបានបង្កើតចេញពីគំនិតដែលយើងខ្ញុំបានទទួលពីសហគមន៍រួមជាមួយគំនិតផ្ទាល់ខ្លួនរបស់យើងមួយចំនួន និងគម្រោងនានាដែលទទួលបានពីផែនការសង្កាត់ជិតខាងនិងផែនការដឹកជញ្ជូនដែលមានស្រាប់ ដូចជាផែនការមេសម្រាប់ការជិះកង់ (Bike Master Plan), ផែនការមេសម្រាប់ផ្លូវឆ្លងកាត់ (Transit Master Plan) និងផែនការមេសម្រាប់ផ្លូវអ្នកថ្មើរជើង (Pedestrian Master Plan)។

ខណៈពេលគម្រោងចម្រុះធំៗ នៅតែមាននៅក្នុងផែនការរបស់យើងនោះ យើងខ្ញុំទទួលស្គាល់តម្រូវការសម្រាប់សកម្មភាពបន្ទាន់។ ដូច្នេះបញ្ជីមានគម្រោងដែល 1) អាចបញ្ចប់ក្នុងរយៈពេលមួយឆ្នាំ និង 2) ការចំណាយថវិកាតិចជាង $100,000 ដុល្លារ។ វាជាបំណងប្រាថ្នារបស់យើង ដែលគម្រោងជាច្រើននឹងត្រូវអនុវត្តឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានក្នុងរយៈពេលតិចជាងមួយឆ្នាំ។

## ការរៀបចំផែនការរួមគ្នា

បន្ទាប់ពីការបិទសន្លឹកឆ្នោតនេះ SDOT នឹងធ្វើការជាមួយក្រុមការងារសហគមន៍ស្ពានទីក្រុងស៊ីតថលខាងលិច (West Seattle Bridge Community Task Force) ដើម្បីពិនិត្យមើលគំនិតយោបល់ដែលបានបង្ហាញដល់យើងខ្ញុំតាមរយៈការបញ្ជាក់ពីការកំណត់លក្ខខណ្ឌថវិកា ជម្លោះដែលទាក់ទងនឹងការដឹកជញ្ជូនដែលមានសក្តានុពលសមធម៌ សុវត្ថិភាព ភាពចល័តទីកន្លែង និរន្តរភាព ភាពអាចរស់នៅបាន និងការគាំទ្រសហគមន៍។

យើងខ្ញុំនឹងខិតខំព្យាយាមធ្វើអ្វីៗទាំងអស់ ដើម្បីគោរពដល់មតិយោបល់និងសំណើរបស់អ្នកនៅសង្កាត់ជិតខាង។ ទោះយ៉ាងណាក៏ដោយ ក៏មិនមែនគម្រោងទាំងអស់ នឹងអាចដំណើរការឆ្ពោះទៅមុខបាន ទេ។ នៅពេលផែនការនានាត្រូវបានបង្កើតឡើង យើងខ្ញុំនឹងរៀបចំកិច្ចប្រជុំតាមដានជាមួយសង្កាត់ជិតខាងរបស់អ្នក ដើម្បីពិភាក្សា និងបង្កើតផែនការមួយសម្រាប់សកម្មភាព។

នៅពេលយើងខ្ញុំយល់ដឹងកាន់តែច្បាស់ពីការពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុនៃសេដ្ឋកិច្ចថ្មីនេះ យើងខ្ញុំនឹងធ្វើការជាមួយលោកអ្នកដើម្បីកំណត់ទំហំគម្រោងឱ្យសមស្របទៅនឹងបញ្ហាប្រឈមនានាដែលយើងទាំងអស់គ្នាមាន។ មតិយោបល់របស់អ្នក នឹងផ្តល់ជូនយើងខ្ញុំនូវការកំណត់ចាប់ផ្តើមមួយសម្រាប់ការធ្វើឱ្យទីក្រុងស៊ីតថលខាងលិច West Seattle និងសហគមន៍នៅជុំវិញមានដំណើរការនិងមានសុវត្ថិភាព។

## ការកំណត់ពេលវេលា

សប្តាហ៍នៃថ្ងៃទី 6 ខែកក្កដា៖ ផែនការអ្នកនៅសង្កាត់ជិតខាងត្រូវបានផ្សព្វផ្សាយជូនដល់សហគមន៍ និងសន្លឹកឆ្នោតដោយបើកចំហ

ថ្ងៃទី 6 - 31 ខែកក្កដា៖ សហគមន៍ផ្តល់អាទិភាពដល់គម្រោងសង្កាត់ជិតខាង

សីហា៖ SDOT និងក្រុមការងារសហគមន៍ WSB Community Task Force ធ្វើការវិភាគមតិយោបល់របស់សហគមន៍និងបង្កើតផែនការមួយ

## យើងខ្ញុំនៅទីនេះ ដើម្បីជួយលោកអ្នក

យើងខ្ញុំនៅទីនេះ ដើម្បីជួយជាជំនួយបច្ចេកទេសនិងភាសា ឆ្លើយសំណួរដែលលោកអ្នកអាចមានអំពីដំណើរការនេះ និងបញ្ជាក់អំពីអ្វីមួយដែលលោកអ្នកមិនអាចយល់។ លោកអ្នកអាចទាក់ទងយើងខ្ញុំតាម westseattlebridge@seattle.gov ឬតាមទូរស័ព្ទលេខ 206-400-7511។